ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

## ស្តីពី

## លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំឆ្នាំ២០១៧

នៅក្នុងឆ្នាំ២០១៧នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ:

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖**

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន០២លើក

-ទទួលសារតាំងចំនួន០២លើក

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន១១លើក និងសម័យប្រជុំពេញអង្គចំនួន០៣លើក និងប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០៣លើក

-អនុញ្ញាតឲ្យគណៈប្រតិភូជាន់ខ្ពស់ជាតិ អន្តរជាតិ អង្គទូត និងអង្គការក្រៅរដ្ឋាភិបាលនានា ចូលជួបសម្តែងការគួរសម សវនាការ និងសំណេះសំណាលចំនួន២៨លើក

-អញ្ជើញជាអធិបតី និងចូលរួមជាកិត្តិយសក្នុងកម្មវិធីផ្សេងៗចំនួន៦៣លើក

-អញ្ជើញចុះមូលដ្ឋានតាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន៣៨លើក

-បានចុះហត្ថលេខាលើព្រះរាជក្រមចំនួន៣៨ច្បាប់ ព្រះរាជក្រឹត្យចំនួន៨៥ច្បាប់ ទទួលព្រះរាជសារព្រះរាជទានសិទ្ធិចំនួន១២៣ច្បាប់ ទទួលសំណើពីរាជរដ្ឋាភិបាលចំនួន១១១សំណើ ពីរដ្ឋសភាចំនួន០៥សំណើ ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចំនួន០១សំណើ ពីប្រធានស្តីទីព្រឹទ្ធសភាចំនួន០២សំណើ ពីក្រុមប្រឹក្សារាជម្មនុញ្ញចំនួន០២សំណើ ពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចំនួន០១សំណើ និងធ្វើសំណើក្នុងនាមប្រមុខរដ្ឋស្តីទីចំនួន០១សំណើ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើលិខិតផ្សេងៗចំនួន១៨៥ច្បាប់ ព្រមទាំងជ្រាបជាព័ត៌មានចំនួន៧៣១ច្បាប់ ។



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

**១.២.ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា បាន :**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០២លើក

-អញ្ជើញដឹកនាំ និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន ១៤លើក សម័យប្រជុំពេញអង្គចំនួន០៦លើក និងប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០៤លើក

-អញ្ជើញបំពេញបេសកកម្មក្រៅប្រទេសចំនួន០១លើក

-ទទួលបដិសណ្ឋារកិច្ចគណៈប្រតិភូជាន់ខ្ពស់ជាតិ អន្តរជាតិ អង្គទូត និងអង្គការក្រៅរដ្ឋាភិបាលនានា ចំនួន០៥លើក

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗចំនួន០៦លើក

-អញ្ជើញចុះមូលដ្ឋានតាមបណ្តាខេត្ត-ក្រុង និងរាជធានីភ្នំពេញចំនួន០៨លើក

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៩៤ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៦៩៥ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ព្រឹទ្ធសភា បាន :**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន១៥លើក សម័យប្រជុំពេញអង្គចំនួន០៧លើក និងប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០៤លើក

-អញ្ជើញជាអធិបតីក្នុងពិធីថ្ងៃសុន្ទរកថាបើក និងបិទ វេទិកាភូមិភាគទី៤ ភូមិភាគទី៨ នៅខេត្តប៉ៃលិន និងខេត្តរតនគិរី ចំនួន០២លើក

-អញ្ជើញជាអធិបតី និងចូលរួមជាកិត្តិយសក្នុងសិក្ខាសាលា សន្និសីទ សន្និបាត មហាសន្និបាតក្នុងប្រទេស និងក្រៅប្រទេស រួមទាំងពិធីផ្លូវការផ្សេងៗចំនួន៤៤លើក

-អញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាការងាររវាងក្រុមសមាជិក សមាជិកាភូមិភាគទី៣ និងថ្នាក់ដឹកនាំទូទាំងស្រុក និងក្រុង នៅខេត្តកណ្តាល

-អនុញ្ញាតឲ្យគណៈប្រតិភូជាន់ខ្ពស់ជាតិ និងអន្តរជាតិ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារចំនួន០៧លើក

-អញ្ជើញចូលរួមប្រជុំការងារសមាគមមិត្តភាពកម្ពុជា-ចិន ចំនួន០២លើក

-អញ្ជើញជួបសំណេះសំណាល ចែកអំណោយដល់ប្រជាពលរដ្ឋ សិស្សានុសិស្ស និងក្រុមប្រឹក្សាឃុំ សង្កាត់ នៅតាមបណ្តាខេត្តនានាចំនួន២៣លើក

-អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ

ដោយឥតគិតថ្លៃ នៅខេត្តកណ្តាល ខេត្តពោធិ៍សាត់ ខេត្តត្បូងឃ្មុំ និងខេត្តកំពង់ឆ្នាំង ចំនួន១០លើក

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១,៩៦៨ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៩៤៣ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំពេញអង្គព្រឹទ្ធសភា**

-ព្រឹទ្ធសភាប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន២០លើក ប្រជុំពេញអង្គចំនួន០៧ លើក និងប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០៤លើក និងបានពិនិត្យឲ្យយោបល់លើសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ចំនួន២២ច្បាប់ ។

**៣.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងឆ្នាំ២០១៧នេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម តាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម:

**៣.១. មុខងារនីតិកម្ម**

-ប្រជុំកែសម្រួលបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងក្រមសីលធម៌សភា

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយតំណាងរាជរដ្ឋាភិបាល តំណាងរដ្ឋសភា ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីស្នើច្បាប់ចំនួន០៩ និងសេចក្តីព្រាងច្បាប់ចំនួន១៣

-គណៈកម្មការពិសេសប្រជុំពិនិត្យ ពិភាក្សាអំពីការរៀបចំសេចក្តីស្នើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ឯកសារ និងនីតិវិធីពាក់ព័ន្ធ

-ប្រជុំពិគ្រោះយោបល់សេចក្តីព្រាងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ ។

**៣.២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-អញ្ជើញចុះបេសកកម្មតាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន២១លើក ដើម្បីសិក្សាឈ្វេងយល់ពីការអនុវត្តច្បាប់ ការផ្សព្វផ្សាយច្បាប់ ការអនុវត្តគោលនយោ-បាយនានា ពិសេសគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ

គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព និងការអនុវត្តសិទ្ធិមនុស្ស នៅខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពត ខេត្តតាកែវ ខេត្តពោធិ៍សាត់ ខេត្តព្រៃវែង ខេត្តត្បូងឃ្មុំ ខេត្តកណ្ដាល ខេត្តប៉ៃលិន ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង ខេត្តក្រចេះ ខេត្តកំពង់ធំ ខេត្តរតនគិរី ខេត្តមណ្ឌលគិរី និងខេត្តកំពង់ឆ្នាំង ។

## ៣.៣.មុខងារតំណាង

-បានរៀបចំវេទិកាសាធារណៈចំនួន០៧លើក នៅភូមិភាគទី១ ភូមិភាគទី៤ ភូមិភាគទី៥ភូមិភាគទី៦ និងភូមិភាគទី៨ស្តីពី ការបូកសរុបលទ្ធផលការអនុវត្តផែនការអភិវឌ្ឍន៍មូលដ្ឋាន ឃុំ សង្កាត់ និងថ្នាក់ក្រោមជាតិធានានូវសុវត្ថិភាពមូលដ្ឋាន, ការផ្តល់សេវាសាធារណៈ និងការចូលរួមរបស់មហាជនក្នុងការអភិវឌ្ឍមូលដ្ឋានភូមិ ឃុំ សង្កាត់, កិច្ចពិគ្រោះយោបល់សាធារណៈ និងពង្រឹងសមត្ថភាពការងាររកសាងផែនការអភិវឌ្ឍន៍មូលដ្ឋាន, ការពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤, ការផ្សព្វផ្សាយសមិទ្ធផលសំខាន់ៗរបស់ព្រឹទ្ធសភា និងភាពជាតំណាងរបស់ក្រុមសមាជិកព្រឹទ្ធសភា, ការពន្យល់អំពីការបោះឆ្នោត និងការផ្តល់វិភាគទាន និងវេទិកាស្តីពី ស្ត្រី និងច្បាប់

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគនានា បើកកិច្ចប្រជុំចំនួន១១លើក ដើម្បីរៀបចំកម្មវិធី បូកសរុបលទ្ធផលការងារសម្រេចបានប្រចាំខែនីមួយៗ និងបានចុះសិក្សាឈ្វេងយល់អំពីវឌ្ឍនភាពក្រោយរៀបចំវេទិកាតាមភូមិភាគ បញ្ហាប្រឈម និងវិធានការដោះស្រាយ ការពង្រឹងសមត្ថភាព និងការលើកកម្ពស់សេវាសាធារណៈនៅថ្នាក់ក្រោមជាតិជាមួយក្រុមប្រឹក្សា ឃុំ សង្កាត់ ស្រុក ខ័ណ្ឌ ខេត្ត ក្រុង និងក្រុមប្រឹក្សារាជធានី ព្រមទាំងបានរៀបចំ និងចូលរួមសិក្ខាសាលា កិច្ចប្រជុំ និងពិធីផ្សេងៗ នៅខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តប៉ៃលិន

-បានទទួលពាក្យបណ្តឹងចំនួន៥៤ករណី បញ្ជូនពាក្យបណ្តឹងទៅអាជ្ញាធរ និងក្រសួងមានសមត្ថកិច្ចដោះស្រាយចំនួន៥៨ករណី ទទួលលិខិតឆ្លើយតបអំពីលទ្ធផលនៃការដោះស្រាយពាក្យបណ្តឹងរបស់ក្រសួង ស្ថាប័ននានាចំនួន០៧ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន៥៨ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន៥៨ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង និងស្ថាប័នពាក់ព័ន្ធចំនួន៨៩ករណី

-សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្ដាខេត្ត ក្រុង រាជធានីទូទាំងប្រទេសចំនួន២,០៩៩លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៨២៣លើក ។

**៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ :**

ថ្នាក់ដឹកនាំ សមាជិក សមាជិកាគណៈកម្មការនានារបស់ព្រឹទ្ធសភា បានអញ្ជើញទៅបំពេញបេសកកម្មក្រៅប្រទេសចំនួន២៨លើក ដើម្បីចូលរួមកិច្ចប្រជុំ ទស្សនកិច្ចសិក្សា សន្និបាត សន្និសីទ សិក្ខាសាលា វេទិកា និងពិធីផ្សេងៗ នៅសាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋហ្វីជី សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋបារាំង សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពសហព័ន្ធរុស្ស៊ី ព្រះរាជាណាចក្រថៃឡង់ដ៍ ព្រះរាជាណាចក្រជប៉ុន ប្រទេសប៊ែលហ្ស៊ិក ប្រទេសបង់ក្លាដេស ប្រទេសហុងគ្រី ប្រទេសសិង្ហបុរី ប្រទេសឥណ្ឌូនេស៊ី ប្រទេសលុចហ្សំបួរ ប្រទេសស៊ុយអែត ប្រទេសឥណ្ឌា និងប្រទេសតួកគី។

ថ្ងៃអង្គារ ១៤រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)